| |
|---|
| តុលាការខេត្ត<br>សៀមរាប-ឧត្តរមានជ័យ<br>សាលក្រម<br>លេខ ៣៩ ត ចុះថ្ងៃទី ២៩<br>ខែ មីនា ឆ្នាំ ២០០៦<br>សំណុំរឿងព្រហ្មទណ្ឌ<br>លេខ ៧៥៥ ចុះថ្ងៃទី ២៩<br>ខែ ធ្នូ ឆ្នាំ ២០០៥ |

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការខេត្តសៀមរាប-ឧត្តរមានជ័យ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅនាទីតុលាការខេត្តសៀមរាប-ឧត្តរមានជ័យ នាថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៦ ដោយមានសមាសភាព :

**ចៅក្រមជំនុំជំរះ**

លោក [redacted] ចៅក្រមតុលាការខេត្ត

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមតុលាការខេត្ត

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីតុលាការខេត្ត

ដើម្បីជំនុំជំរះរឿងព្រហ្មទណ្ឌលេខ ៧៥៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥ ដែលមានជនជាប់ចោទ :

-ឈ្មោះ ឃ ចរ ហៅ ទ ជ ភេទស្រី អាយុ ១៧ឆ្នាំ ជាតិខ្មែរ កើតនៅភូមិអូរអំពិល ឃុំអូរអំពិល ស្រុកសិរីសោភ័ណ្ឌ ខេត្តបន្ទាយមានជ័យ សាសនាព្រះពុទ្ធ កំរិតវប្បធម៌ថ្នាក់ទី៣ថ្មី ទីលំនៅមុនពេលចាប់ខ្លួននៅភូមិក្បាលស្ពាន ឃុំក្បាលស្ពាន ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ របររកស៊ីនៅផ្ទះ នៅលីវ ។ ឪពុកឈ្មោះ ឃ ស (រ) ម្តាយឈ្មោះ ណ ឈ (រ) ទោសពីមុន *គ្មាន* ។

ឃុំខ្លួនថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥ ។

ត្រូវចោទពីបទ រំលោភលើសេចក្តីទុកចិត្ត ប្រព្រឹត្តនៅភូមិសាលាកន្សែង ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៥ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

មានកញ្ញាមេធាវី សៅ គន្ធា ជាមេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ ឃ ចរ ហៅ ទ ជ ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ស សរ ភេទប្រុស អាយុ ៣២ឆ្នាំ ជាតិខ្មែរ របររកស៊ីរត់ម៉ូតូឌុប មានទីលំនៅបច្ចុប្បន្នភូមិសាលាកន្សែង ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។

សាលក្រមនេះបានចូលជាស្ថាពរនៅថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៦
ដោយពុំមានភាគីណាមួយប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ឡើយ ។
សៀមរាប,ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៦
ក្រឡាបញ្ជី
ហត្ថលេខា និង ត្រា
[redacted]

ក្រែង

## ការប្រព្រឹត្តិរបស់ជនជាប់ចោទមានដូចតទៅ

ឈ្មោះ យ ចរ ហៅ ទ ជ មានស្រុកកំណើតនៅខេត្តបន្ទាយមានជ័យ បានមកខេត្តសៀមរាប ស្នាក់នៅផ្ទះជួលភូមិសាលាកន្សែង ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប ។

breach of trust
Breach of contract ?

នៅថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៥ វេលាម៉ោង ១១ព្រឹកឈ្មោះ យ ចរ ហៅ ទ ជ បានមកនិយាយជួលម៉ូតូរបស់ឈ្មោះ ស សរ ជាអ្នករត់ម៉ូតូនៅផ្ទះជួលជិតគ្នា ម៉ូតូធុនសេ ១២៥ ពណ៌ខ្មៅ ស៊េរី២០០៤ ដោយជួលក្នុង ០១ម៉ោង ៥.០០០រ០០ (ប្រាំពាន់រៀល) ដោយប្រាប់ថា ជិះទៅលេងអង្គរ ។ ឈ្មោះ ស សរ ក៏យល់ព្រម ព្រោះធ្លាប់ស្គាល់នៅផ្ទះជួលជិតគ្នា ឈ្មោះ យ ចរ ហៅ ទ ជ ពេលជួលបានហើយ ក៏ជិះម៉ូតូនោះទៅលេងអង្គររួចត្រឡប់មកផ្ទះវិញ ក៏មានគំនិតទៅលេងឪពុកម្តាយនៅប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។ នៅព្រឹកថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៥ បាននាំម្តាយទៅលេងបងស្រីឈ្មោះ មុំ ប្តីឈ្មោះ ទិត នៅភូមិបឹងអារក្ស ឃុំបឹងអារក្ស ស្រុកបវេល ខេត្តបាត់ដំបង ដោយទុកម៉ូតូផ្ញើនឹងផ្ទះឈ្មោះ ម ទ ។

នៅថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៦ ឈ្មោះ ស សរ មិនឃើញឈ្មោះ យ ចរ ហៅ ទ ជ យកម៉ូតូមកឱ្យខ្លួនវិញ ក៏ទៅតាមរកជួបឈ្មោះ យ ចរ ហៅ ទ ជ នៅភូមិបឹងអារក្ស ឃុំបឹងអារក្ស ស្រុកបវេល ខេត្តបាត់ដំបង ។ ឈ្មោះ ស សរ បានសួររកម៉ូតូរបស់ខ្លួននាង យ ចរ ហៅ ទ ជ បានឆ្លើយថា ម៉ូតូចោរលួចបាត់ហើយនៅខេត្តបន្ទាយមានជ័យ ។ ឈ្មោះ ស សទ ក៏បានឱ្យនាំមកប្រាប់កន្លែងបាត់ម៉ូតូ ពេលមកដល់ខេត្តបន្ទាយមានជ័យម៉ោងប្រហែល ០៨យប់ក៏បាននាំនាង យ ចរ ហៅ ទ ជ មកខេត្តសៀមរាបតែម្តង រួចប្តឹងសមត្ថកិច្ចធ្វើការឃាត់ខ្លួននៅថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥ ។ បន្ទាប់មកសមត្ថកិច្ចបានធ្វើការដកហូតម៉ូតូដែលផ្ញើនៅផ្ទះ ម ទ ខេត្តបាត់ដំបងប្រគល់ឱ្យម្ចាស់ដើមវិញហើយ ។

## នាពេលសវនាការ

ជនជាប់ចោទឈ្មោះ យ ចរ ហៅ ទ ជ បានឆ្លើយថា កាលពីថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៥ វេលាម៉ោង ១១ព្រឹកខ្លួនបានទៅសុំជួលម៉ូតូពីឈ្មោះ ធៀម តែម៉ូតូគាត់រវល់ គាត់ក៏បានទៅនិយាយឈ្មោះ ស សរ ជួលឱ្យខ្លួន១ ក៏ស្គាល់ពេញ្ហោះ ស សរ ប្រាប់ថា ជិះដើរលេងមួយថ្ងៃ ក្រោយពីជួលម៉ូតូបានហើយ ខ្លួនជិះទៅលេងអង្គរដល់កន្លែងលក់សំបុត្រ ខ្លួនបានត្រឡប់មកផ្ទះវិញចិត្តចង់ទៅលេងឪពុកម្តាយនៅប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។ ពេលទៅដល់ប៉ោយប៉ែត ខ្លួនបានជួបនឹងឪពុកម្តាយហើយបានសំរាកនៅទីនោះមួយយប់ ។ លុះព្រឹកឡើងខ្លួនបាននាំម្តាយមកលេងបងស្រីឈ្មោះ ជ ម នៅភូមិបឹងអារក្ស ឃុំបឹងអារក្ស ស្រុកបវេល ខេត្តបាត់ដំបង។ ពេលខ្លួនជិះទៅដល់ផ្ទះបានជួបបងស្រី និង ប្តីរបស់គាត់ ដោយបានសំរាកនៅទីនោះចំនួន ០២យប់ជាមួយម្តាយខ្លួន ដោយផ្ញើម៉ូតូនេះជាមួយបងប្រុសឈ្មោះ ទិត ដោយផ្ទះរបស់បងគ្មានកន្លែងទុក ។ នៅពេលល្ងាចថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០០៥ ពេលខ្លួនកំពុងចុះមុជទឹកក៏បានជួបនឹងម្ចាស់ម៉ូតូគេទៅដល់បានសួរខ្លួនថា ម៉ូតូទុកនៅឯណា ខ្លួនបានប្រាប់ថា ម៉ូតូខ្លួនផ្ញើទុកផ្ទះគេសុំឱ្យម្ចាស់ជិះទៅវិញ ។ ប៉ុន្តែម្ចាស់ម៉ូតូបែរជានាំខ្លួនមកខេត្តសៀមរាបទៅវិញ រួចប្តឹងនគរបាលចាប់ខ្លួនតែម្តង ។ រឿងនេះខ្លួនគ្មានគំនិតទុច្ចរិតតែបំបាត់ម៉ូតូឈ្មោះ ស សរ ទេ ។

-ជនរងគ្រោះឈ្មោះ ស សរ បានឆ្លើយថា កាលពីថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៥ ឈ្មោះ ជៀន ហៅ រ៉ា បានមកនិយាយជួលម៉ូតូខ្លួនក្នុង ០១ម៉ោងតម្លៃ ៥.០០០រៀល (ប្រាំពាន់រៀល) ថា ទៅយកលុយពីគេ ខ្លួនមិនដឹងជាកន្លែងណាទេ ខ្លួនក៏យល់ព្រមជួលឱ្យទៅ ព្រោះធ្លាប់នៅផ្ទះជួលជិតគ្នា ។ ពេលជួលបានហើយគេជិះចេញទៅបាត់រហូតខ្វះ ១៥នាទីទៀតគ្រូវជា ០១ម៉ោងឃើញគេជិះត្រឡប់មកផ្ទះវិញ ប្រហែលជា ១០នាទីគេបានជិះម៉ូតូចេញ

ទៅក្រៅវិញក៏បាត់រហូត ។ ខ្លួនមិនបានតាមរកទេនៅចាំរហូត ដល់ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៥ ទើបខ្លួនទៅតាមរ ព្រោះគេមានលេខទូរស័ព្ទធ្លាប់ទាក់ទង ពេលនោះខ្លួនបានយកលេខទូរស័ព្ទទាក់ទងទៅគេឆ្លើយថា គេនៅប៉ោយប៉ែ នៅភូមិរីវីតែអូរឬ ឃុំមិនស្គាល់ ខ្លួនក៏បានទៅតាមរកជាមួយឈ្មោះ ម៉ៅ ពេលទៅដល់បានរកផ្ទះនោះឃើញដោយបា ជួបតែឪពុក ពេលខ្លួនសួរទៅថា ឈ្មោះ ទ ជ ទៅភូមិបឹងអារក្ស ឃុំបឹងអារក្ស ស្រុកបវិល ខេត្តបាត់ដំបង ខ្លួន បានទៅតាមរក ហើយក៏បានជួបឈ្មោះ ជឿន កំពុងចងពុងរៀបចំចុះងូតទឹក ខ្លួនក៏បានចូលទៅសួរពីរឿងម៉ូតូរបរ ខ្លួន គេបានឆ្លើយថា ម៉ូតូនោះចោរលួចបាត់ហើយនៅខេត្តបន្ទាយមានជ័យ ខ្លួនក៏បាននិយាយថា បើបាត់នៅកន្លែ ណាឱ្យមកចង្អុលប្រាប់កន្លែងនោះ គេក៏បានមកតាមខ្លួនរហូតដល់ខេត្តបន្ទាយមានជ័យនៅម៉ោង ៨:៣០នាទីក៏មា ឡានដឹកត្រីមកខេត្តសៀមរាប ខ្លួនក៏បាននាំគ្នាជិះមកកាន់ខេត្តសៀមរាបតែម្តង ពេលមកដល់ខ្លួនបានមកប្តឹងសមត្ថកិ ទើបគេសារភាពថា ម៉ូតូនោះគេទុកផ្ញើនឹងផ្ទះឈ្មោះ ម ទ រួចក៏សមត្ថកិច្ចទៅដកហូតយកម៉ូតូនោះមកឱ្យខ្លួនវិ ហើយ ។ នៅក្នុងរឿងនេះ ខ្លួនមិនប្តឹងទាមទារសំណងជម្ងឺចិត្តទេ ព្រោះបានទទួលម៉ូតូវិញហើយ ។

## តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា

ឆ្លងតាមការសួរដេញដោលរួចមកឃើញថា ជនជាប់ចោទបានសារភាពនូវទោសកំហុសរបស់ខ្លួនដោយ បាននិយាយជួលម៉ូតូពីឈ្មោះ ស សរ ពិតប្រាកដមែនក្នុង ០១ម៉ោងតម្លៃ ៥.០០០៛០០ ដោយជួលទៅរហូត ពេ ដែលម្ចាស់គេទៅតាមជួបសួរពីរឿងម៉ូតូ គេបានឆ្លើយថា ម៉ូតូនោះបានបាត់ទៅហើយ នេះសរបញ្ជាក់ថា ជនល្មើស មានចេតនាទុច្ចរិតពិតប្រាកដ ដូច្នេះមានពិរុទ្ធភាពចូនលួមលើឈ្មោះ យ ចរ ហៅ ទ ជ ពីបទរំលោភលើសេចក្តីទុ ចិត្តប្រព្រឹត្តនៅភូមិសាលាកន្សែង ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៥ ។

ហេតុនេះសូមតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ ២៨២ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០០៦ ទុកជាបានកា ពេញទាំងមូល ។

សូមតុលាការផ្តន្ទាទោសជនជាប់ចោទតាមបញ្ញត្តិមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១( ខែ កញ្ញា ឆ្នាំ ១៩៩២ ។

កញ្ញាមេធាវី សៅ ភក្ត្រា ការពារសិទ្ធិជនជាប់ចោទឈ្មោះ យ ចរ ហៅ ទ ជ បានធ្វើសេចក្តីសន្និដ្ឋាន ថា ឆ្លងតាមការសួរដេញដោលរួចមកឃើញថា កូនក្តីខ្លួនមិនទាន់បានប្រព្រឹត្តបទល្មើសទេ ព្រោះកូនក្តីខ្លួនមិនទាន់ បានលក់ម៉ូតូទៅឱ្យជនទីពី ហើយដោយគ្មានខកខានមិនបានយកម៉ូតូមកឱ្យតាមកិច្ចសន្យាព្រោះគ្នាមានផ្ទៃពោះ តែ កូនក្តីខ្លួនមិនបានប្រាប់ដំណឹងទៅម្ចាស់ម៉ូតូទេនៅឆ្ងាយមិនអាចទាក់ទងបាន ហេតុនេះសូមតុលាការមេត្តាលើកលែង ទោសដល់កូនក្តីខ្លួនដោយអនុគ្រោះ ។

ជនជាប់ចោទឈ្មោះ យ ចរ ហៅ ទ ជ បាននិយាយសំដីចុងក្រោយបង្អស់ថា សូមតុលាការមេត្តាបន្ធូរ បន្ថយទោសដល់ខ្លួនផង ។

- បានស្តាប់ចម្លើយជនជាប់ចោទ
- បានស្តាប់ចម្លើយជនរងគ្រោះ
- បានឃើញសៀវភៅតាមដានកូនមានផ្ទៃពោះឈ្មោះ យ ចរ ចេញដោយមន្ទីរពេទ្យ ជ័យវរ្ម័នទី ៧ ប្រចាំខេត្តសៀមរាប ។
- បានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ
- បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវី

-បានស្តាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

## <u>តុលាការខេត្តសៀមរាប_ឧត្តរមានជ័យ</u>

ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>យល់ឃើញថា</u>

-កាលពីថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៥ វេលាម៉ោង ១១:៣០នាទីព្រឹកឈ្មោះ **យ ចរ** ហៅ **ទ ជ** បាននិយាយជួលម៉ូតូសេ ១២៥ ពណ៌ខ្មៅ ស៊េរី២០០៤ ពីឈ្មោះ **ស សរ** ក្នុង ១ម៉ោងតម្លៃ ៥.០០០រ០០ (ប្រាំពាន់រៀល) រយៈពេលមួយថ្ងៃ ។ ពេលបានម៉ូតូហើយជនជាប់ចោទជិះម៉ូតូគេចខ្លួនទៅលាក់ទុកនៅទីកដីខេត្តបាត់ដំបង ដោយកុហកម្ចាស់ម៉ូតូថា ម៉ូតូនោះចោរលួចបាត់ហើយ ។

-អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ **យ ចរ** ហៅ **ទ ជ** មានចែង និង ផ្តន្ទាទោសតាមមាត្រា ៤៦ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

-ប៉ុន្តែបើពិនិត្យឱ្យជិតដល់ទៅឃើញថា ជនជាប់ចោទឈ្មោះ **យ ចរ** ហៅ **ទ ជ** ស្ថិតជាអនីតិជនខ្វះការពិចារណា ជីវភាពក្រលំបាក ហើយទើបតែប្រព្រឹត្តបទល្មើសជាលើកដំបូង ។

-តាមមាត្រា ៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលមានចែងអំពីស្ថានសំរាលទោស និង គ្រាប្រណីទោសចំពោះអនីតិភាព ។ ម្យ៉ាងទៀតជនជាប់ចោទមានផ្ទៃពោះចូលដល់ខែទីប្រាំបួនហើយ តុលាការ និង ពិចារណាដល់បញ្ហានេះតាមសភាពជាក់ស្តែង ។

-ជនរងគ្រោះឈ្មោះ **ស សរ** មិនបានប្តឹងទាមទារសំណងជម្ងឺចិត្តទេ នោះតុលាការមិនពិចារណាដល់បញ្ហានេះឡើយ ។

## <u>ហេតុដូច្នេះវិនិច្ឆ័យសេចក្តី</u>

១-ផ្តន្ទាទោសឈ្មោះ **យ ចរ** ហៅ **ទ ជ** ដាក់ពន្ធនាគារកំណត់ ០៣ខែ (បីខែ) គិតពីថ្ងៃឃុំខ្លួន ។

ពីបទ **រំលោភលើសេចក្តីទុកចិត្ត** តាមមាត្រា ៤៦ និង មាត្រា ៦៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩២ ប្រព្រឹត្តនៅភូមិសាលាកន្សែង ឃុំស្វាយដង្គំ ស្រុកសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០០៥ ។

២-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទ កំបាំងមុខជនរងគ្រោះ បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**

**ហត្ថលេខា និង ត្រា**

[redacted]

**ចៅក្រមជំនុំជំរះ**

**ហត្ថលេខា និង ត្រា**

[redacted]